01054086

E333

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 01 / 2015
ម៉ោង (Time/Heure): 14:00
មន្ត្រីមទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **អង្គជំនុំជម្រះសាលាដំបូងដាក់ឯកសារថ្មីមួយទៅក្នុងសំណុំរឿង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន**

**១.** នៅក្នុងសៀវភៅដែលនិពន្ធដោយលោក Ben Kiernan ដែលមានចំណងជើងថា របប ប៉ុល ពត ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ នៅក្នុងប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មានការលើកឡើងអំពី "របាយការណ៍មួយស្តីអំពីដំណើរទស្សនកិច្ចរបស់សាស្ត្រាចារ្យជនជាតិអង់គ្លេសម្នាក់ និងអ្នកសារព័ត៌មានជនជាតិអាមេរិកាំងមួយចំនួន" (ឯកសារ E3/1593 ទំព័រ ៤៤៥ ជើងទំព័រ ២៣)។ នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបង្គាប់ទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ស្នើសុំសំណៅថតចម្លងនៃឯកសារនេះមួយច្បាប់ពីលោក Ben Kiernan។ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤ លោក Ben Kiernan បានឆ្លើយតបដោយបានផ្តល់ឯកសារថតចម្លងជារូបភាព (scanned copy) នៃឯកសារដើមនេះ។ គាត់បានលើកឡើងថា គាត់បានទទួលឯកសារដែលជាទម្រង់រូបភាពពីលោក ខៀវ កញ្ញារិទ្ធ នៅទីក្រុងភ្នំពេញក្នុងអំឡុងឆ្នាំ ១៩៩០។ អង្គភាពបកប្រែភាសាបានបកប្រែសំណៅដើមនៃឯកសារនេះជាភាសាខ្មែរ ទៅជាភាសាអង់គ្លេស និងបារាំងរួចហើយ។

E333

២. អង្គជំនុំជម្រះចាត់ទុកថា ឯកសារនេះបានបំពេញបទដ្ឋាននៃការវាយតម្លៃ*បឋម* (*prima facie*) នូវភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ហើយឯកសារនេះជួយដល់ការស្វែងរកការពិត។ ហេតុដូច្នេះ អង្គជំនុំជម្រះដាក់ឯកសារនេះទៅក្នុងសំណុំរឿង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។